# គោលការណ៍ណែនាំសំខាន់ៗស្តីពីការពាក់ម៉ាស់ជាចាំបាច់

○ ត្រូវពាក់ម៉ាស់តាមការណែនាំដូចតទៅៈ

- (នៅក្នុងផ្ទះ) ត្រូវពាក់ម៉ាសគ្រប់ពេល
- **(នៅខាងក្រៅ)** ❶ក្នុងករណីមានការជួបជុំការសម្តែងនិងព្រឹត្តិការណ៍ផ្សេងៗត្រូវតែពាក់ម៉ាស់ដោយមិនគិតពីចម្ងាយ ❷ត្រូវពាក់ម៉ាស់ ប្រសិនបើវាពិបាករក្សាចម្ងាយជាង ២ ម៉ែត្រពីអ្នកដទៃ

☞ ទោះជាយ៉ាងណាការផាកពិន័យរហូតដល់ ១០០,០០០ វ៉ុនអាចនឹងត្រូវបានគេពិន័យ ប្រសិនបើមិនបានពាក់ម៉ាស់នៅតាមកន្លែងដែលងាយនឹងឆ្លងរីករាលដាលនៃជំងឺ ដោយសារតែមិនបានបញ្ជាក់ច្បាស់លាស់ពីក្រុមមនុស្សដែលជួបជុំគ្នា។

○ ម៉ាស់មិនចាំបាច់ពាក់វានៅពេល

- (នៅក្នុងផ្ទះ) នៅពេលដែលនៅម្នាក់ឯងក្នុងចន្លោះបែងចែកដូចជាផ្ទះឬការិយាល័យឯកជនឬជាមួយអ្នករស់នៅជាមួយគ្នាដូចជាគ្រួសារ ដោយគ្មានអ្នកមកពីខាងក្រៅនៅជាមួយ
- (នៅខាងក្រៅ) ត្រូវរក្សាចម្ងាយពីគ្នាជាង ២ ម៉ែត្រពីអ្នកដទៃដែលស្ថិតនៅខាងក្រៅនៅពេល (ហាត់ប្រាណ ដើរលេងកំសាន្តក្នុងសួនឧទ្យានជាដើម។ ល។)
- (ផ្សេងទៀត) ក្នុងករណីសកម្មភាពដែលពិបាកក្នុងការពាក់ម៉ាស់ដូចជា (ការញ៉ាំចំណីអាហារ ការហែលទឹក ការងូតទឹក ការដុសធ្មេញ ការសម្តែង ការលេងកីឡាជាដើម។ល។)។

<ការណែនាំស្តីពីលក្ខណៈវិនិច្ឆ័យសម្រាប់ការដាក់ពិន័យតាមបទបញ្ជារដ្ឋបាលចំពោះការពាក់ម៉ាស់>

○ **ប្រធានបទនិងរយៈពេលនៃការដាក់បទបញ្ជារដ្ឋបាលនិងការពិន័យ**

- **(មូលដ្ឋានច្បាប់)** មាត្រា៤៩ នៃច្បាប់ស្តីពីការការពារជំងឺឆ្លង (វិធានការបង្ការចំពោះជំងឺឆ្លង) មាត្រា៨៣(ត្រៀមពិន័យ)
- **(រយៈពេលបទបញ្ជារដ្ឋបាល)** រយៈពេលដែលអាជ្ញាធរផ្នែករដ្ឋបាល (រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងសុខុមាលភាព នាយកមជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជំងឺនៃសាធារណរដ្ឋកូរ៉េ អភិបាលខេត្តឬអភិបាលក្រុង / ប្រធានកងកម្លាំងប្រដាប់អាវុធ) ត្រូវបានចាត់តាំង អនុវត្តចាំបាច់នៅក្នុង " កម្រិតព្រមាន / កម្រិតធ្ងន់ធ្ងរនៃការប្រុងប្រយ័ត្នចំពោះជំងឺឆ្លង។

**-ការផាកពិន័យនៃការមិនគោរព: ការពិន័យនឹងប្រតិបត្តិចាប់ពីថ្ងៃទី១៣ខែ១១ឆ្នាំ២០២០នេះតទៅ បន្ទាប់ពីរយៈពេល១ខែនៃការ ណែនាំអំពីការពិន័យដែលគិតចាប់ពី**ថ្ងៃទី១៣ខែ១០ឆ្នាំ២០២០ដល់ថ្ងៃទី១២ខែ១១ឆ្នាំ២០២០។

※ការណែនាំឱ្យពាក់ម៉ាស់ក្នុងករណីមានការល្មើសនឹងបទបញ្ជានិងមិនប្រតិបត្តិនឹងទទួលបានការដាក់ផាកពិន័យ។

**-ចំនួនទឹកប្រាក់ពិន័យ:** ចំពោះការអ្នកល្មើសត្រូវផាកពិន័យយ៉ាងច្រើនបំផុតត្រឹម១០ម៉ឺនវ៉ុន និងចំពោះអ្នកគ្រប់គ្រងនិងនិយោជកត្រូវពិន័យយ៉ាងច្រើនបំផុតត្រឹម៣០០ម៉ឺនវ៉ុន(ការល្មើសលើកដំបូងត្រូវពិន័យ១៥០ម៉ឺនវ៉ុននិងការល្មើសចាប់លើសពី២ដងឡើងទៅ នឹងត្រូវពិន័យ៣០០ម៉ឺនវ៉ុន)។

**-ប្រភេទនៃម៉ាស់: ម៉ាស់ដែលអាចប្រើប្រាស់បានមានម៉ាស់សុខភាព(ម៉ាស់KF94/KF80។ល។) ម៉ាស់ការពារការឆ្លង(KF-AD)ម៉ាស់សម្រាប់ការវះកាត់និងម៉ាស់ក្រណាត់(សំឡី)ដែលអាចបាំងច្រមុះនិងមាត់បាន។**

※ការមិនអនុញ្ញាតិនៃការបាំងមុខដោយសាច់ក្រណាត់ដូចជាម៉ាស់សំណាញ់ ម៉ាស់អេប៉ុង និងកន្សែងបង់កជាដើម។ល។

**-វិធីប្រើប្រាស់: គប្បីប្រើម៉ាស់ដើម្បីបាំងមាត់និងច្រមុះឱ្យមានសុវត្ថិភាព។**

※ការមិនប្រើប្រាស់ម៉ាស់មានដូចជាក្នុងករណីមិនពាក់ម៉ាស់ឬបានពាក់ម៉ាស់ប៉ុន្តែមិនបានបាំងមាត់និងច្រមុះ។

**. តំបន់ដែលត្រូវត្រួតត្រានេះជាសេចក្តីណែនាំនៅក្នុងទូទាំងប្រទេស ប៉ុន្តែចំពោះការដែលអាចប្រែប្រួលនៅក្នុង**

ស្រុកទៅតាមស្ថានភាពវិវត្តន៍នៃជំងឺកូវីត១៩(អាស្រ័យទៅតាមការបញ្ជារបស់រដ្ឋបាលក្នុងស្រុក)។

| តំបន់ដែលត្រូវត្រួតត្រា | កម្មវត្ថុ |
|---|---|
| **អទិភាព/កន្លែងគ្រប់គ្រងទូទៅ**<br>※ ភាពដែលអាចផ្លាស់ប្តូរចំពោះការរក្សាគម្លាត | **រដ្ឋបាល(ម្ចាស់សម៉ីខ្លួន)និងអ្នកដែលប្រើប្រាស់បរិក្ខានិងទីកន្លែងត្រូវកំណត់ទៅលើកម្រិតរក្សាគម្លាត។** |
| **មធ្យោបាយធ្វើដំណើរសារធារណ:** | អ្នកប្រើប្រាស់មធ្យោបាយធ្វើដំណើរសារធារណ:មានដូចជាឡានក្រុងរថភ្លើងក្រោមដីនិងតាក់ស៊ី។ល។ |
| **តំបន់ប្រជុំជននិងវាលតវ៉ាសាធារណ:** | មានអ្នករៀបចំ(ម្ចាស់កម្មវិធី)និងអ្នកចូលរួមនៃកម្មវិធីទាំងនៅក្នុងនិងក្រៅនៃព្រឹត្តិការណ៍ប្រមូលផ្តុំ |
| **មណ្ឌលសុខភាពនិងឱសថស្ថាន** | **អ្នកប្រើប្រាស់និងអ្នកគ្រប់គ្រង(សហការី)នៃមណ្ឌលសុខភាពនិងឱសថស្ថាន** |
| **កន្លែងថែទាំសុខភាពនិងកន្លែងថែទាំយប់ថ្ងៃ** | អ្នកគ្រប់គ្រងនិងបុគ្គលិកដែលជាអ្នកថែទាំអ្នកជំងឺនៅក្នុងកន្លែងថែទាំសុខភាពនិងអ្នកមកកន្លែងថែទាំនិងមណ្ឌលថែទាំ |
| **ទីកន្លែងសាសនា** | **អ្នកចូលរួមនិងអ្នកគ្រប់គ្រង(សហការី)នៃទីកន្លែងសាសនា** |
| **ពហុកីឡាដ្ឋាន** | **អ្នកគ្រប់គ្រង (ប្រតិបត្តិករ) អ្នកប្រើប្រាស់ពហុកីឡាដ្ឋាន** |
| **ទីកន្លែងការងារដែលមានហានិភ័យខ្ពស់** | **អ្នកគ្រប់គ្រង (ប្រតិបត្តិករ) អ្នកប្រើប្រាស់ (មជ្ឈមណ្ឌលហៅទូរស័ព្ទ មជ្ឈមណ្ឌលចែកចាយនិងភស្តុភា) ទីកន្លែងការងារដែលមានហានិភ័យខ្ពស់។** |
| **កិច្ចប្រជុំនិងព្រឹត្តិការណ៍នានាដែលមានមនុស្សលើសពី ៥០០នាក់<br>ត្រូវតែរាយការណ៍និងពិភាក្សាដោយរដ្ឋបាលក្នុងតំបន់។** | **អ្នកគ្រប់គ្រង (អ្នករៀបចំ) អ្នកប្រើប្រាស់ (អ្នកចូលរួម) កិច្ចប្រជុំនិងព្រឹត្តិការណ៍នានាដែលមានមនុស្សលើសពី ៥០០នាក់ ត្រូវតែរាយការណ៍និងពិភាក្សាដោយរដ្ឋាភិបាលក្នុងតំបន់។** |

* អ្នកប្រើប្រាស់មានន័យថាជា អ្នកគ្រប់គ្រងប្រតិបត្តិករ ឬនិយោជិត មានន័យថាអ្នករាល់គ្នាដែលបានចូលក្នុងកន្លែងកម្មវិធីនេះ។ល។

**○ (ករណីលើកលែង និង ការលើកលែងចំពោះការពិន័យ)**

| | |
|---|---|
| **ការលើកលែង** | **•មនុស្សដែលមិនទាន់គ្រប់អាយុ ១៤ ឆ្នាំ។**<br>**•មនុស្សដែលមានការលំបាកក្នុងការពាក់ ឬដោះម៉ាស់ដោយខ្លួនឯងដោយគ្មានជំនួយពីមនុស្សជុំវិញ ដូចជា ជនពិការ-ជនដែលមានសតិមិនគ្រប់គ្រាន់ជាដើម។ល។**<br>**•មនុស្សដែលបានរកឃើញដោយវេជ្ជសាស្ត្រថាពិបាកក្នុងដកដង្ហើមនៅពេលពាក់ម៉ាស ដូចជា ជំងឺផ្លូវដង្ហើម។ល។** |
| **ករណីលើកលែង** | **•នៅពេលញ៉ាំអាហារ ឬផឹកភេសជ្ជះ។**<br>**•នៅពេលងូតទឹក ឬនៅក្នុងទឹក ដូចជា អាងហែលទឹក និងកន្លែងងូតទឹក។ល។**<br>**•នៅពេលអនុវត្តសកម្មភាពអនាម័យផ្ទាល់ខ្លួន ដូចជា លុបមុខ និងដុសធ្មេញ។ល។**<br>**•នៅពេលពិបាកពាក់ម៉ាស់ អំឡុងពេលព្យាបាល ដូចជា ពិនិត្យសុខភាព វះកាត់ ព្យាបាល និងការប្រើឱសថ។ល។**<br>**• នៅពេលថតរូបធ្វើការបកស្រាយជាភាសាសញ្ញា(ការកំណត់ចំពោះការថតជាផ្លូវការនៅក្នុងព្រឹត្តិការណ៍ផ្សេងៗ) និងការផ្សព្វផ្សាយការសម្តែង (ការផ្សាយជាលក្ខណ:ឯកជន ដូចជាយូធូបត្រូវបានកំណត់ចំពោះការថតនៅទីកន្លែងឯកជន) និងការសម្តែងដែលត្រូវបង្ហាញមុខរបស់តួអង្គ (នៅលើឆាកសម្តែង)ជាដើម។ល។**<br>**•នៅពេលសម្តែងនិងការប្រកួតប្រជែង ការប្រកួត, ល្បែង ការលេងភ្លេង និងកីឡាករជាដើម។ល។**<br>**•នៅក្នុងកម្មវិធី ឪពុកម្តាយទាំងសងខាង កូនកំលោះ និងកូនក្រមុំ នៅក្នុងសាលមង្គលការ។ល។** |

- នៅពេលមានការព្រួយបារម្ភថាម៉ាសអាចរារាំងភារកិច្ចសុវត្ថិភាព (អ្នកបើកបរយន្តហោះ) នៅក្នុងអំឡុងពេលបម្រើការងារ។
- នៅពេលអ្នកត្រូវដោះម៉ាស់ចេញ ដូចជា ការកំណត់អត្តសញ្ញាណ ដើម្បីពិនិត្យមើលសាម៉ីខ្លួន។